ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
លេខ៖ បព ៤៤/២០២៥ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

# លទ្ធផលនៃកិច្ចពិគ្រោះយោបល់ក្រៅផ្លូវការក្នុងទម្រង់ពង្រីក ស្តីពីការអនុវត្តកិច្ចព្រមព្រៀងជាឯកច្ឆន្ទប្រាំចំណុច ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៥ ទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី

នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៥ តបតាមការអញ្ជើញរបស់**ឯកឧត្តម ដាតុ សេរី យូតាម៉ា ហាជីមហាម៉ាដ ប៊ីន ហាជី ហាហ្សាន** រដ្ឋមន្ត្រីក្រសួងការបរទេសម៉ាឡេស៊ី **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមកិច្ចពិគ្រោះយោបល់ក្រៅផ្លូវការក្នុងទម្រង់ពង្រីកស្តីពីការអនុវត្តកិច្ចព្រមព្រៀងជាឯកច្ឆន្ទប្រាំចំណុច ( 5PC ) នៅទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី។

រដ្ឋមន្ត្រីការបរទេសអាស៊ានបានកោតសរសើរដល់ការដឹកនាំប្រកបដោយសមត្ថភាព និងបុរេសកម្មរបស់ម៉ាឡេស៊ី ក្រោមប្រមុខ**ឯកឧត្តម អាន់វ៉ា អ៊ីប្រាហ៊ីម** នាយករដ្ឋមន្ត្រីម៉ាឡេស៊ី និងបានកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ប្រេសិតពិសេសប្រធានអាស៊ានស្តីពីមីយ៉ាន់ម៉ា ក្នុងការសម្របសម្រួលកិច្ចសន្ទនាប្រកបដោយបរិយាបន្ន ការជំរុញឱ្យបញ្ឈប់អំពើហិង្សា និងការលើកកម្ពស់ការផ្តល់ជំនួយមនុស្សធម៌ ជាពិសេសនៅបន្ទាប់ពីគ្រោះរញ្ជួយដីដ៏មហន្តរាយ កាលពីដើមឆ្នាំនេះ។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** បានរំឭកឡើងវិញនូវការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់កម្ពុជាក្នុងការគាំទ្រកិច្ចខិតខំប្រឹងប្រែងរួមរបស់អាស៊ានលើការជំរុញការអនុវត្ត 5PC និងជួយមីយ៉ាន់ម៉ាក្នុងការដោះស្រាយវិបត្តិរបស់ខ្លួនតាមរយៈដំណើរការនយោបាយដែលដឹកនាំ និងគ្រប់គ្រងដោយមីយ៉ាន់ម៉ាខ្លួនឯង។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**ក៏បានបញ្ជាក់ឡើងវិញអំពីសារៈសំខាន់នៃយន្តការត្រីភាគីអាស៊ាន និងត្រីភាគីក្នុងទម្រង់ពង្រីក ក៏ដូចជាសំណើប្រកបដោយភាពច្នៃប្រឌិតផ្សេងៗទៀត ដើម្បីធានាឱ្យបាននូវវឌ្ឍនភាព ការលើកកម្ពស់សង្គតិភាព និងភាពស៊ីសង្វាក់គ្នា ព្រមទាំងរក្សាបាននូវសន្ទុះវិជ្ជមាន។

បន្ថែមពីលើនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**បានជួបពិភាក្សាការងារទ្វេភាគីជាមួយ**ឯកឧត្តម ដាតុ សេរី យូតាម៉ា ហាជីមហាម៉ាដ ប៊ីន ហាជី ហាហ្សាន** រដ្ឋមន្ត្រីការបរទេសម៉ាឡេស៊ី។ នៅក្នុង**ឱកាសនោះ** **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**បានសម្តែងនូវអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះម៉ាឡេស៊ី ដែលបានផ្តល់ការសម្របសម្រួល និងកិច្ចខិតខំប្រឹងប្រែងឥតសំចៃ ក្នុងការជួយកម្ពុជានិងថៃ ដោះស្រាយជម្លោះព្រំដែន

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីមែល: mfaic@mfaic.gov.kh

ដោយសន្តិវិធី។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**បានសម្តែងការអបអរសាទរចំពោះជោគជ័យរបស់ម៉ាឡេស៊ី ក្នុងនាមជាប្រធានអាស៊ាន នៅឆ្នាំនេះ។ **រដ្ឋមន្ត្រីទាំងពីរ**ក៏បានពិភាក្សាអំពីការពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីឱ្យកាន់តែស៊ីជម្រៅ ដោយបានឯកភាពគ្នារៀបចំកិច្ចប្រជុំគណៈកម្មការចម្រុះលើកទី៣ សម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគីរវាងកម្ពុជានិងម៉ាឡេស៊ី ក្នុងឆ្នាំ២០២៦ នៅប្រទេសម៉ាឡេស៊ី។

ថ្ងៃសៅរ៍ ៤កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែតុលា ឆ្នាំ២០២៥